# ជំងឺរលាកសាច់ដុំបេះដូងបន្ទាប់ពីការចាក់វ៉ាក់សាំង COVID-19 ៖ ប្រការដែលឪពុកម្ដាយនិងមនុស្សវ័យក្មេងគួរដឹង

Vaccinate WA
CovidVaccineWA.org

## តើជំងឺរលាកសាច់ដុំបេះដូងគឺជាអ្វី?

ជំងឺរលាកសាច់ដុំបេះដូង (និងជំងឺរលាកស្រោមបេះដូង) គឺជាពាក្យដែលពិពណ៌នាអំពីការហើមរលកខាងក្នុង ឬជុំវិញបេះដូង។ រោគសញ្ញាទូទៅរួមមានឈឺទ្រូង ពិបាកដកដង្ហើម និងមានអារម្មណ៍ថាបេះដូងរបស់អ្នកលោតញាប់ខ្លាំង។ ប្រព័ន្ធភាពស៊ាំរបស់រាងកាយជារឿយៗអាចបង្កឲ្យមានការហើមរលាកនេះ ដែលជាប្រតិកម្មទៅនឹងការឆ្លងជំងឺដូចជាវីរុស។

## ជំងឺរលាកសាច់ដុំបេះដូងមិនកើតមានជាទូទៅទេ ហើយកម្រនឹងបង្កឲ្យស្លាប់បាត់បង់ជីវិតណាស់។

មានករណីជំងឺរលាកសាច់ដុំបេះដូងតិចជាង 200,000ករណីនៅសហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ ដែលមានអត្រាស្លាប់បាត់បង់ជីវិតតិចជាង 2%។ មិនមានអ្នកស្លាប់ដោយសារជំងឺរលាកសាច់ដុំបេះដូងដែលត្រូវបានកំណត់ថាបណ្ដាលមកពីការចាក់វ៉ាក់សាំងជំងឺ COVID-19 នៅសហរដ្ឋអាមេរិកទេ។

- គេមិនដឹងថាវាមានការឆ្លងរាលដាលនេះទេ។
- ករណីភាគច្រើនគឺកម្រិតស្រាល
- ការព្យាបាលជាធម្មតាមានកម្រិតតិចតួច ដោយផ្ដោតលើការគ្រប់គ្រងរោគសញ្ញា

## តើមានការតភ្ជាប់ទៅនឹងការចាក់វ៉ាក់សាំងជំងឺ COVID-19 ដែរឬទេ?

អាចមាន។ ហានិភ័យក្រោយការចាក់វ៉ាក់សាំងគឺកម្រកើតមានណាស់ ប៉ុន្តែវាអាចកើតឡើង។ ជំងឺរលាកសាច់ដុំបេះដូង ក៏កើតឡើងចំពោះអ្នកដែលមិនទទួលការចាក់វ៉ាក់សាំងដែរ។

ដោយសារតែគេមិនអាចបដិសេធបាន ដូច្នេះទើប Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) បានកំណត់ថាមាន "ទំនាក់ទំនងដែលអាចកើតមាន" រវាងជំងឺរលាកសាច់ដុំបេះដូងនិងជំងឺរលាកស្រោមបេះដូង និងវ៉ាក់សាំងជំងឺ COVID-19 ប្រភេទ mRNA (ផលិតដោយក្រុមហ៊ុន Moderna និង Pfizer-BioNTech) ។

## តើសញ្ញានិងរោគសញ្ញាអ្វីខ្លះដែលខ្ញុំគួរដឹងបន្ទាប់ពីការចាក់វ៉ាក់សាំងរួច?

ករណីភាគច្រើនកើតឡើងចំពោះក្មេងប្រុសវ័យជំទង់និងវ័យក្មេងដែលមានអាយុក្រោម 30ឆ្នាំ។ រោគសញ្ញាមានជាធម្មតាក្រោយការចាក់ដូសទី2។

CDC ណែនាំថា អ្នកដែលទើបតែបានទទួលការចាក់វ៉ាក់សាំងថ្មីត្រូវស្វែងរកទទួលការថែទាំព្យាបាលវេជ្ជសាស្ត្រ ប្រសិនបើពួកគេកើតមានរោគសញ្ញាទាំងនេះក្រោយទទួលការចាក់វ៉ាក់សាំង ជាពិសេសនៅសប្ដាហ៍ដំបូងក្រោយការចាក់វ៉ាក់សាំង៖

- ចុកដើមទ្រូង
- ដង្ហក់
- មានអារម្មណ៍ថាមានចង្វាក់បេះដូងលោតញាប់ ញ័រទ្រូង ឬបេះដូងលោតខ្លាំង

ឱកាសដែលអាការៈទាំងនេះកើតមាន គឺតិចតួចបំផុត។ ប៉ុន្តែ ត្រូវស្វែងរកការថែទាំព្យាបាលផ្នែកវេជ្ជសាស្ត្រភ្លាមៗ ប្រសិនបើអ្នកមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំងនេះ។

**សូមចងចាំថា ធម្មតាតែងមានរោគសញ្ញាពីស្រាលទៅមធ្យម**រួមមានគ្រុនក្ដៅ ឈឺក្បាល អស់កម្លាំង និងឈឺសន្លាក់/សាច់ដុំ ក្នុងអំឡុងសប្ដាហ៍ទីមួយ បន្ទាប់ពីទទួលបានវ៉ាក់សាំងជំងឺ COVID-19 ណាមួយ។ ផលរំខានទាំងនេះ ជាធម្មតាតែងចាប់ផ្ដើមកើតមានក្នុងរយៈពេលបីថ្ងៃបន្ទាប់ពីការទទួលវ៉ាក់សាំង ហើយគួរតែកើតមានត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ។

## ការចាក់វ៉ាក់សាំងនៅតែជាជម្រើសដ៏ល្អបំផុត

អត្ថប្រយោជន៍របស់វ៉ាក់សាំងមានច្រើនជាងហានិភ័យនៃជំងឺរលាកសាច់ដុំបេះដូង។ វ៉ាក់សាំងនេះមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការការស្លាប់បាត់បង់ជីវិតនិងជំងឺ រួមទាំងការការពារប្រឆាំងនឹងវីរុសវ៉ារ្យ៉ង់ថ្មីដែលមានគ្រោះថ្នាក់ជាងមុនផងដែរ។

Washington State Department of Health

DOH 348-835 August 2021 - Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនដែលស្ដាប់មិនឮ ឬស្ដាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីម៉ែល civil.rights@doh.wa.gov។